លីកាដូ

LICADHO

# អត្ថបទនៃការពិត របស់លីកាដូ

## ស្តីពីការលក់ និងការផ្ទេរកម្មសិទ្ធិដីដោយខុសច្បាប់ នៅកំពង់ឆ្នាំង

នៅឆ្នាំ១៩៨០ ប្រជាពលរដ្ឋពីរគ្រួសារបានចូលមករស់នៅលើដីលំនៅដ្ឋាន នឹងបានបង្កបង្កើតផលលើដីស្រែពីរកន្លែងក្នុងភូមិដើមពពេល ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ប្រជាពលរដ្ឋទាំងពីរគ្រួសារនេះបានរស់នៅនឹងធ្វើកសិកម្មលើដីស្រែចាប់តាំងពីពេលនោះរហូតដល់សព្វថ្ងៃ ស្របតាមផ្លូវច្បាប់ដែលពួកគេបានក្លាយជាម្ចាស់កម្មសិទ្ធិករលើដីនោះ។ ប៉ុន្តែពេលនេះ គ្រួសារទាំងពីរកំពុងប្រឈមមុខទៅនឹងបណ្តឹងព្រហ្មទណ្ឌពីភាគីម្ខាងដោយចោទប្រកាន់ថាបានប្រព្រឹត្តហិង្សាលើគូវិវាទក្នុងជម្លោះទាមទារកាន់កាប់ដីកម្មសិទ្ធិ ។

សវនាការរឿងជម្លោះដីមួយនេះ ដើមឡើយត្រូវបើកសវនាការនៅថ្ងៃ ទី៩ ខែកក្កដា ឆ្នាំ២០០៧, វេលាម៉ោង ២រសៀលនេះនៅតុលាការខេត្តកំពង់ឆ្នាំង។ ប៉ុន្តែ ដោយសារអវត្តមានមន្ត្រីអាជ្ញាធរមូលដ្ឋានដ៏សំខាន់ម្នាក់ក្នុងអង្គសនវិការក្តីនេះ អង្គជំនុំជំរះត្រូវបានលើកពេលទៅធ្វើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧, វេលាម៉ោង ៧:៣០ ព្រឹកវិញ ។ លោក **ហម ស៊ុនរិទ្ធ** មេធាវីជាន់ខ្ពស់របស់អង្គការលីកាដូ នឹងធ្វើជាតំណាងឱ្យផលប្រយោជន៏គ្រួសាររងគ្រោះទាំងពីរ ។



នៅឆ្នាំ១៩៨៥ បុរសម្នាក់ឈ្មោះ **ឆើត ឆេន** បានសុំទិញដីស្រែពីរកន្លែងពីប្រជាពលរដ្ឋទាំងពីរគ្រួសារនោះ ប៉ុន្តែ ពួកគាត់មិនព្រមលក់ ។ ក្រោយមក **ឆើត ឆេន** បានទាក់ទងបុរសម្នាក់ទៀតនៅក្នុងភូមិឈ្មោះ **កែ អ៊ុត** ហើយឈ្មោះនេះបានលួចលក់ដីស្រែទាំងពីរកន្លែងនោះដោយមិនឱ្យសាម៉ីម្ចាស់ដីដឹងឡើយ។ តាមពិតឈ្មោះ **កែ អ៊ុត** នេះពុំមែនជាម្ចាស់ដីស្រែទាំងពីរកន្លែងនោះឡើយ។ ថ្ងៃមួយក្នុងឆ្នាំ២០០៦ នៅពេលមន្ត្រីសុរិយោដី និង តុលាការចុះទៅវាស់វែងដីនោះ **កែ អ៊ុត** បានសារភាពថា គាត់បានលួចលក់ដីស្រែពីរកន្លែងនោះឱ្យទៅ ឈ្មោះ **ឆើត ឆេន** មែនក្នុងតម្លៃ ១៦០.០០០ រៀល (ជាតម្លៃប្រាក់រៀលក្នុងឆ្នាំ១៩៨៥)។

ក្រោយមក **ឆើត ឆេន** ដែលជាឪពុកក្មេកបានធ្វើប័ណ្ណកម្មសិទ្ធិដីពីការិយាល័យសុរិយោដីដោយដាក់ឈ្មោះកូនប្រសារគាត់ឈ្មោះ **សុខ ប៊ុនធឿន** មានតួនាទីជាប្រធានការិយាល័យផែនការស្រុកកំពង់ត្រឡាច ។ រីឯ ឈ្មោះ **ឪ ធុនវុទ្ធ** ក៏ជាកូនប្រសាររបស់ **ឆើត ឆេន** ដែរ ។

ដូច្នេះ ដីស្រែពីរកន្លែងរបស់កសិករទាំងពីរគ្រួសារនេះមានប័ណ្ណកម្មសិទ្ធិកាន់កាប់ត្រួតគ្នា ដែលបណ្តាលឱ្យមានទំនាស់ដីនេះកើតឡើង។ មួយច្បាប់ គឺជាប័ណ្ណកម្មសិទ្ធិដើមរបស់កសិករទាំងពីរគ្រួសារ ដែលចេញដោយការិយាល័យសុរិយោដីខេត្តនៅខែតុលា ឆ្នាំ១៩៩៣ ។ ទោះបីជាប័ណ្ណកម្មសិទ្ធិនោះ ត្រូវបានហៅថាជាប័ណ្ណកម្មសិទ្ធិដីលំនៅដ្ឋានក្តី ក៏ក្នុងប័ណ្ណបានបញ្ជាក់ថាដីនោះជាដីលំនៅដ្ឋាន និងដីស្រែផងដែរ។ ចំណែកឯលោក **សុខ ប៊ុនធឿន** វិញមានប័ណ្ណកម្មសិទ្ធិធ្វើនៅខែកញ្ញា ឆ្នាំ១៩៩៤ ដោយការិយាល័យសុរិយោដីខេត្ត ដោយនៅក្នុងប័ណ្ណរបស់គាត់បានបញ្ជាក់ថាត្រឹមជាប្រភេទដីស្រែប៉ុណ្ណោះ ។

នៅក្នុងខែសីហា ឆ្នាំ២០០៥ **សុខ ប៊ុនធឿន** បាននាំនគរបាលពីរនាក់ដែលប្រដាប់ដោយអាវុធអាកា-៤៧ ទៅគំរាមប្រជាពលរដ្ឋម្ចាស់ដីដែលកំពុងដាំដុះនៅលើដីនោះ។ គាត់បានគំរាមកសិករទាំងពីរគ្រួសារឱ្យឈប់ធ្វើស្រែនៅលើដីដែលគាត់អះអាងថាដីរបស់គាត់ ហើយថែមទាំងបាននាំកសិករទាំងនោះទៅអធិការដ្ឋាននគរបាលស្រុកថែមទៀត ។ នៅក្នុងអធិការដ្ឋាននគរបាល-កសិករទាំងពីរគ្រួសារបានបង្ហាញប័ណ្ណកម្មសិទ្ធិ ដែលធ្វើនៅឆ្នាំ១៩៩៣ ដល់មន្ត្រីនគរបាល ប៉ុន្តែ មន្ត្រីនោះបាននិយាយថា ប័ណ្ណកម្មសិទ្ធិទាំងនេះហួសសម័យគេឈប់ប្រើប្រាស់ ហើយព្រមទាំងគ្រវែងផុតពីតុរបស់គាត់ថែមទៀត។ ពេលនោះកសិករទាំងពីរគ្រួសារបាននិយាយថា ពួកខ្លួនពុំអាចធ្វើប័ណ្ណទាំងនេះបានទេមានតែមន្ត្រីរាជការតែប៉ុណ្ណោះដែលជាអ្នកធ្វើប័ណ្ណនេះ ហើយមន្ត្រីនគរបាលនោះបាននិយាយថា មានតែប័ណ្ណកម្មសិទ្ធធ្វើនៅឆ្នាំ១៩៩៤ ប៉ុណ្ណោះដែលមានសុពលភាព ។

នៅ ខែកញ្ញា ឆ្នាំ២០០៥ **សុខ ប៊ុនធឿន** បានប្តឹងប្រជាពលរដ្ឋទាំងពីរគ្រួសារដោយយោងតាមមាត្រា ២៥៣ នៃច្បាប់ដីធ្លីឆ្នាំ២០០១។ យោងតាមមាត្រានេះបានចែងថា *"ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនៈវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ ទៅ ២៥.០០០.០០០ រៀល និង/ឬ ដាក់ពន្ធនាគារពី ៦ ខែ ដល់ ២ ឆ្នាំ ដោយពុំទាន់គិតបញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស ។*

នៅខែកក្កដា ឆ្នាំ២០០៦ **សុខ ប៊ុនធឿន** ចង់លក់ដីទំនាស់នោះឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះ ។ បុរសនោះបានយកប័ណ្ណកម្មសិទ្ធិផ្ទៀងផ្ទាត់ នឹងសាកសួរអំពីប្រវត្តិដីនោះជាមួយប្រជាពលរដ្ឋជិតខាង ។ ក្រោយពីដឹងថា ដីនោះជាដីរបស់ប្រជាពលរដ្ឋពីរគ្រួសារទើបបុរសនោះមិនហ៊ានទិញដីនោះវិញ។

មុនពេលមានទំនាស់ ម្ចាស់ដីទាំងពីរគ្រួសារពុំដែលដឹងថាមានគេលួចលក់ដីរបស់ខ្លួនទេ ហើយក៏ពុំដឹងថាមានប័ណ្ណកម្មសិទ្ធិត្រួតលើដីរបស់ពួកគាត់ដែរ ។

នៅក្នុងខែមិថុនា ឆ្នាំ២០០៦ តុលាការបានបញ្ជាឱ្យធ្វើការស៊ើបអង្កេតភាពមិនប្រក្រតីនៃប័ណ្ណកម្មសិទ្ធិរបស់ **សុខ ប៊ុនធឿន** ។ ចៅក្រមស៊ើបអង្កេតបានរកឃើញថា នៅក្នុងប័ណ្ណកម្មសិទ្ធិដីរបស់ភាគីទំនាស់ទាំងពីរនោះពុំមាន

បញ្ជាក់ព្រំប្រទល់ច្បាស់លាស់ទេ ហើយបានបញ្ជូនប័ណ្ណទាំងនោះទៅការិយាល័យសុរិយោដីខេត្ត ដើម្បីផ្ទៀងផ្ទាត់។ មិនតែប៉ុណ្ណោះ លោកចៅក្រមក៏បានប្រាប់ប្រជាពលរដ្ឋម្ចាស់ដី ឱ្យបន្តធ្វើស្រែលើនោះតទៅទៀតតាមធម្មតា។

ការិយាល័យសុរិយោដីបានគូសប្លង់ដីរបស់គ្រួសារទាំងនេះសារឡើងវិញ។ **ឆើត ឆេន** និង **ឌី ធុនវុទ្ធ** បានទទួលដីមួយចំណែក ហើយពីរគ្រួសារនេះបានមួយចំណែក ។ ប៉ុន្តែ មន្ត្រីសុរិយោដីមិនបានដោះស្រាយទំនាស់កម្មសិទ្ធិដីរវាងប្រជាពលរដ្ឋពីរគ្រួសារ និង បុរសម្នាក់ទៀតនៅក្នុងភូមិដោយយោងតាមច្បាប់ទេ។



**ឆើត ឆេន** និង **សុខ ប៊ុនធឿន** ក៏បានលួចធ្វើប័ណ្ណកម្មសិទ្ធិលើដីសាធារណៈដែលនៅជិតដីប្រជាពលរដ្ឋពីរគ្រួសារនោះផងដែរ ។

យោងតាមមូលដ្ឋានច្បាប់ ការទាមទារកម្មសិទ្ធិ និងបណ្តឹងព្រហ្មទណ្ឌរបស់ **សុខ ប៊ុនធឿន** មានចំណុចខ្សោយច្រើនយោងតាមការវិភាគខាងក្រោម:

**ទី ១**:-យោងតាមមាត្រា ៣០ នៃច្បាប់ដីធ្លីបានចែងថា "*បុគ្គលទាំងឡាយណាដែលបានអាស្រ័យផលភោគដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ ឆ្នាំយ៉ាងតិចតិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះ លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធ*"។ យ៉ាងហោចណាស់រស់នៅលើដីនោះរយៈពេល៥ឆ្នាំ-មុនឆ្នាំ២០០១ ជននោះមានសិទ្ធិបានដីនោះជាកម្មសិទ្ធិឯកជនផ្ទាល់ខ្លួន។ ដូច្នេះ គ្រួសារទាំងពីរខាងលើបានបន្តធ្វើស្រែលើដីទំនាស់នោះ ចាប់តាំងពីឆ្នាំ១៩៨០ ហើយពួកគាត់មានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនោះយ៉ាងពិតប្រាកដ។

**ទី ២**:- យោងតាមមាត្រា ២៥៣ បណ្តឹងព្រហ្មទណ្ឌដែលបានប្តឹងនោះពុំសមស្របឡើយ។ ទំនាស់ដីនេះជាករណីរដ្ឋប្បវេណីពុំមែនករណីព្រហ្មទណ្ឌទេ។ ប្រជាពលរដ្ឋទាំងនោះ ពុំដែលបានប្រើអំពើហិង្សាលើ **សុខ ប៊ុនធឿន** ទេ។ លើសពីនេះទៅទៀតមាត្រា ២៥៣ ចែងថា ដើម្បីធ្វើបណ្តឹងព្រហ្មទណ្ឌម្ចាស់ដីត្រូវតែជាម្ចាស់ផ្ទាល់ ។ តាមករណីខាងលើបានបង្ហាញថា **សុខ ប៊ុនធឿន** បានដឹងថា គ្រួសារទាំងពីរនេះបានកាន់កាប់ដីនោះតាំងពីយូរមកហើយ គឺមុនពេលគាត់ធ្វើប័ណ្ណកម្មសិទ្ធិទៅទៀត។

ករណីនេះ គឺជាករណីរំលោភដីធ្លីដែលប្រព្រឹត្តដោយអាជ្ញាធរមូលដ្ឋាន ដ៏ធំមួយនៅខេត្តកំពង់ឆ្នាំង ។ នៅចន្លោះខែមករា ឆ្នាំ២០០៥ និងខែមិថុនា ឆ្នាំ២០០៧ លីកាដូបានស៊ើបអង្កេត ២១ ករណីលើទំនាស់ដីធ្លី ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួនជាង ៥០០ នាក់នៅទូទាំងខេត្ត។

**ព័ត៌មានបន្ថែម សូមមេត្តាទាក់ទង:**

-លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវ កេក** ប្រធានអង្គការលីកាដូ ទូរស័ព្ទលេខ :០១២ ៩៤០ ៦៤៥